ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ...១៣៣៦... ឧវប.ករ.កសក

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការចុះត្រួតពិនិត្យនិងវាយតម្លៃស្ថានភាពប្រតិបត្តិករផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់រូបវន្តបុគ្គលនិងនីតិបុគ្គលជាប្រតិបត្តិករកំពុងធ្វើអាជីវកម្មផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ជ្រាបថា៖ នៅពេលខាងមុខនេះ ក្រុមការងារក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងចុះត្រួតពិនិត្យសកម្មភាពការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតរបស់ប្រតិបត្តិករទាំងអស់ (ដែលទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ឬហៅថាអាជ្ញាបណ្ណ)។

តាមរយៈលទ្ធផលនៃការត្រួតពិនិត្យនិងវាយតម្លៃនេះ ក្រសួងសង្ឃឹមថានឹងអាចចូលរួមចំណែកជួយកែលម្អ កែតម្រូវ និងផ្ដល់ការគាំទ្រនានាឱ្យបានត្រូវមុខសញ្ញា ដើម្បីពង្រឹងនិងលើកកម្ពស់ការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត។

អាស្រ័យហេតុនេះ សូមប្រតិបត្តិករផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតទាំងអស់ជ្រាប និងត្រៀមលក្ខណៈចូលរួមសហការអនុវត្តតាមសេចក្ដីជូនដំណឹងនេះដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឱ្យមានប្រសិទ្ធភាព ដើម្បីផលប្រយោជន៍អាជីវកម្មផ្ទាល់ខ្លួនផង និងឧត្តមប្រយោជន៍សាធារណជន និងសង្គមជាតិផង។

ថ្ងៃ ព្រហស្បតិ៍ ៤ កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០២៤
រដ្ឋមន្ត្រី

ហែម វណ្ណឌី

**ចម្លងជូន:**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីគោរពជូនជ្រាប"
- សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
- គ្រប់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយបន្ត និងសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ